# នេះជាពត៍មានណែនាំប្រសិនបើសិក្ខាកាមមិនអាចបន្តធ្វើការនៅក្នុងប្រទេសជប៉ុន

ក្នុងនាមជាសិក្ខាកាម អ្នកត្រូវបានការពារដោយច្បាប់ការងាររបស់រដ្ឋាភិបាលក្នុងប្រទេសជប៉ុន។ប្រសិនបើសិក្ខាកាមមិនអាចបន្តធ្វើការងារដោយសារការរីករាលដាលនៃជំងឺឆ្លងថ្មីកូរ៉ូណានេះ សិក្ខាកាមអាចប្រើប្រាស់ប្រព័ន្ធដូចខាងក្រោមបានដែរហើយសូមកុំស្ទាក់ស្ទើរក្នុងការប្រើប្រាស់វា។

## ប្រាក់ជំនួយនៃការធានារ៉ាប់រងការងារ(ប្រាក់លើកទឹកចិត្តមូលដ្ឋាន)

**ក្នុងអំឡុងពេលអ្នកធ្វើការបានបាត់បង់ការងារយើងផ្តល់អត្ថប្រយោជន៍ចាំបាច់ដើម្បីធ្វើឱ្យជីវិតរបស់ពួកគេអាចរស់នៅបានដោយមានស្ថេរភាព។ ប្រសិនបើអ្នកគ្មានការងារធ្វើដោយសារខាងក្រុមហ៊ុនបានក្ស័យធនហើយលំបាកក្នុងការរកការងារថ្មី បើអ្នកមានលក្ខខណ្ឌជាក់លាក់មិនចំពោះសិក្ខាកាមនោះទេអ្នកអាចស្នើរជំនួយយកប្រាក់ធានារ៉ាប់រងការងារបាន (ប្រាក់លើកទឹកចិត្តមូលដ្ឋាន) ។ (ចំណាំសិក្ខាកាមក៏មានសិទ្ធប្រើប្រាស់ប្រព័ន្ធនេះដូចជនជាតិជប៉ុនផងដែរ)**

### ១ ការដាក់ពាក្យធ្វើការនៅកន្លែងស្វែងរកការងារ

ដើម្បីទទួលបានប្រាក់ឧបត្ថម្ភមូលដ្ឋានបន្ទាប់ពីឈប់រឺចាកចេញពីការងារអ្នកត្រូវដាក់ពាក្យសុំរកការងារនៅកន្លែងស្វែងរកការងារ។

### ២ ការធានារ៉ាប់រងការងារត្រូវមានរយៈពេល១២ខែឬច្រើនជាងនេះ

បន្ទាប់ពីចាកចេញពីការងារអ្នកត្រូវតែមានការបង់ធានារ៉ាប់រងការងារយ៉ាងហោចណាស់១២ខែក្នុងរយៈពេល២ឆ្នាំមុនថ្ងៃដែលបានចាកចេញពីការងារ។ប៉ុន្តែបើសិនជាខាងក្រុមហ៊ុនមិនមានការក្ស័យធុនទេតែក្រុមហ៊ុនត្រូវបញ្ឈប់បុគ្គលិកមួយចំនួននោះការធានារ៉ាប់រងការងារត្រូវមានយ៉ាងហោចណាស់៦ខែក្នុងរយៈពេល១ឆ្នាំមុនថ្ងៃចាកចេញពីការងារ។

**<វិធីស្នើសុំយកការធានារ៉ាប់រង(ប្រាក់លើកទឹកចិត្តមូលដ្ឋាន)>**

- ចាកចេញពីការងារ
- ពាក្យសុំការងារនិងការកំណត់អំពីសិទ្ធិ — សមីខ្លួនត្រូវយកឯកសារដែលត្រូវការទៅដាក់នៅកន្លែងស្វែងរកការងារ។
- ការពន្យល់អំពីការធានារ៉ាប់រង — ប្រគល់ឯកសារនឹងវិញ្ញាបនប័ត្រនៃសិទ្ធិទទួលប្រាក់ជំនួយ។ ពន្យល់ពីវិធីបន្តនៃការធានារ៉ាប់រងការងារ ។
- ការផុតកំណត់រយៈពេលរង់ចាំ — ចាប់ពីថ្ងៃដាក់ពាក្យរយៈពេល៧ថ្ងៃគឺមិនបានគិតនៃការរង់ចាំក្នុងការទទួលប្រាក់ធានារ៉ាប់រងការងារឡើយ។
- ការកំណត់ប្រាក់ជំនួយ — ប្រសិនបើអ្នកឈប់ការងារដោយផ្ទាល់ខ្លួនអ្នកមិនមានសិទ្ធស្នើសុំការធានារ៉ាប់រងការងាររយៈពេល៣ខែបន្ទាប់ពីឈប់ការងារ។
- វិញ្ញាបនប័ត្រអត់ការងារធ្វើ — ការទទួលស្គាល់អត់ការងារ(គោលការណ៍៤សប្តាហ៍ម្តង) ត្រូវយកឯកសារទៅកន្លែងស្វែងរកការងារ។
- ទូទាត់ប្រាក់លើកទឹកចិត្តមូលដ្ឋាន — ប្រាក់លើកទឹកចិត្តមូលដ្ឋាននឹងផ្ញើរទៅធនាគាររបស់អ្នកនៃចំនួនថ្ងៃសរុបដែលអ្នកអត់មានការងារធ្វើ។
- តាមច្បាប់កាលបរិច្ឆេទនៃការបញ្ជាក់របស់អ្នកនឹងត្រូវបានបញ្ជាក់រៀងរាល់៤សប្តាហ៍ម្តង
- ផ្លាស់ប្តូរការងារថ្មី
- បញ្ឈប់ការបើកប្រាក់

ក្រុមហ៊ុនដែលត្រូវបានកាត់បន្ថយម៉ោងធ្វើការរបស់បុគ្គលិកហើយអាចឈានដល់ការបញ្ឈប់បុគ្គលិកក្នុងករណីណាមួយពួកគេអាចស្នើរប្រាក់ឧបត្ថម្ភបានដែលតំរូវអោយពួកគេបំពេញតាមតម្រូវការជាក់លាក់។ ទោះជាយ៉ាងណាក៏ដោយដើម្បីចៀសវាងគុណវិបត្តិបុគ្គលិកពួកគេអាចប្រើប្រាស់ប្រព័ន្ធធានារ៉ាប់រងការងារពេលឈប់សម្រាកបាន។

※ លើសពីនេះទៅទៀតក្នុងមេត្រាទី២៦នៃច្បាប់ស្តីពីស្តង់ដារការងារប្រសិនបើក្រុមហ៊ុនបានបញ្ឈប់បុគ្គលិកពួកគេត្រូវទទួលប្រាក់ជំនួយពីក្រុមហ៊ុនក្នុងរយៈពេលឈប់សម្រាកដើម្បីធានាកំរិតជីវភាពអប្បបរមាររបស់បុគ្គលិកដែលបានសន្ទត់ជាមុន។

**សម្រាប់ពតិមានបន្ថែមសូមទាក់ទងសាកសួរខាងក្រោមហើយយើងក៏ផ្តល់ពត៏មានតាមគេហទំព័រផងដែរ**

**●ប្រាក់ជំនួយនៃការធានារ៉ាប់រងការងារ(ប្រាក់លើកទឹកចិត្តមូលដ្ឋាន)：**

**➢ការិយាល័យសន្តិសុខការងារសាធារណៈការិយាល័យរដ្ឋបាលខេត្ត （កន្លែងស្វែងរកការងារ）**

**https://www.mhlw.go.jp/kyujin/hwmap.html**

**●សូមទំនាក់ទំនងទៅល័ក្ខខ័ណ្ឌការងារប្រាក់ឈ្នួលរួមទាំងប្រាក់ជំនួយពេលឈប់សម្រាក：**

**➢ទូរស័ព្ទពិភាគសារយោបល់សម្រាប់ពលករបរទេស ទូរស័ព្ទបន្ទាន់សម្រាប់ពិគ្រោះយោបល់ល័ក្ខខ័ណ្ឌការងារនឹងពិគ្រោះយោបល់សម្រាប់ជនបរទេស：**

**https://www.check-roudou.mhlw.go.jp/soudan/foreigner.html**

## សេចក្តីណែនាំរបស់អង្គការបណ្តុះបណ្តាលបច្ចេកទេសនឹងបណ្តាញទូរស័ព្ទពិគ្រោះយោបល់នៃភាសាដើមកំណើត

អង្គការបណ្តុះបណ្តាលបច្ចេកទេសបរទេស

- ពេលមានអារម្មណ៍ព្រួយចំពោះការងារឬជីវភាពប្រចាំថ្ងៃ
- ពេលមានអារម្មណ៍ថាប្រាក់ឈ្នួលការងារមិនទទួលបានគ្រប់គ្រាន់រឺខុសតាមគោលការណ៍
- ពេលមានកំហុសឆ្គងហើយនឹងត្រូវបញ្ជូនត្រឡប់ទៅប្រទេសវិញ
- ពេលដែលមិនយល់ច្បាស់អំពីច្បាប់ប្រទេសជប៉ុនរឺមិនមាននរណាម្នាក់ពិគ្រោះយោបល់ជាមួយ

ទទួលពិគ្រោះយោបល់ជាច្រើនរបស់សិក្ខាកាមពលករនៅប្រទេសជប៉ុនជាមួយភាសាដើមកំនើតរបស់អ្នក

សម្រាប់ពត៏មានសម្អិតសុមចុលមើលគេហទំព័រខាងក្រោម（https://www.otit.go.jp）

**ទូរស័ព្ទពិគ្រោះយោបល់ជាភាសារកំនើត（១១:00～១៩:00ហ្វ៊ី）**

| | | |
|---|---|---|
| ・ភាសាវៀតណាម | រាល់សប្តាហ៍：ច័ន្ទ～សុក្រ | TEL：០១២០－២៥០－១៦៨ |
| ・ភាសាចិន | រាល់សប្តាហ៍ ：ច័ន្ទ・ពុធ・សុក្រ | TEL：០១២០－២៥០－១៦៩ |
| ・ភាសាឥណ្ឌូនេស៊ី | រាល់សប្តាហ៍ ：អង្គារ・ពុធ | TEL：០១២០－២៥០－១៩២ |
| ・ភាសាហ្វីលីពីន | រាល់សប្តាហ៍ ：អង្គារ・សៅរ៍ | TEL：០១២០－២៥០－១៩៧ |
| ・ភាសាអង់គ្លេស | រាល់សប្តាហ៍ ：អង្គារ・សៅរ៍ | TEL：០១២០－២៥០－១៤៧ |
| ・ភាសាថៃ | រាល់សប្តាហ៍ ：ពុធ・ សៅរ៍ | TEL：០១២០－២៥០－១៩៨ |
| ・ភាសាខ្មែរ | រាល់សប្តាហ៍ ：ព្រហស្បហ៍ | TEL：១២០－២៥០－៣៦៦ |
| ・ភាសាមិយ៉ាន់ម៉ា | រាល់សប្តាហ៍ ：សុក្រ | TEL：០១២០－២៥០－៣០២ |

厚生労働省・都道府県労働局・労働基準監督署・ハローワーク 2020.5